**Embassy of Japan**
**in the Kingdom of Cambodia**

# Press Release

No. 22 PR-21/EoJ 7 July, 2021

## Online Tanabata 2021

The Embassy of Japan, in collaboration with the Cambodia-Japan Cooperation Center (CJCC) and the Japan Foundation Asia Center (JFAC), will hold "Online Tanabata 2021" from 9-11 July2021, instead of our annual event "Tanabata Festival" organized since 2004, to promote cultural exchanges between Japan and Cambodia.

Tanabata is a Japanese traditional festival, celebrated every year on 7 July in Japan to recall a story of a couple lovers —Weaver princess and Herdsman— in the sky. Based on the Tanabata story, the two lovers are separated by the Amanogawa River (Milky Way) and allowed to meet once a year on 7 July. On the day, Japanese people write their wishes on colorful strips of paper and hang them on bamboo trees to make their wishes come true.

During Online Tanabata 2021 from 9-11 July 2021, there will be various online Japanese cultural activities on Facebook Event Page of Online Tanabata 2021 (Please see the link below) such as Japanese Calligraphy Session, Cooking video by the Ambassador's Chef, Virtual Tokyo Tour by Zoom, Online Japanese Class, Tanabata Narrative Story, Videos of Japanese traditional culture and more. Time schedule of each activity is enclosed.

For media inquiries, please contact Culture and Information Section at 023 217 161 (Ext: 1121) or email: info.jpn@pp.mofa.go.jp. For more information of the festival, please visit Facebook Event Page of Online Tanabata Fesival 2021 at https://fb.me/e/4maLxGM5B

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161*
*Email: info.jpn@pp.mofa.go.jp*
*Official Website: https://www.kh.emb-japan.go.jp/*

## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

No. 22 PR-21/EoJ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១

# ពិធីបុណ្យផ្កាយអនឡាញ២០២១

ស្ថានទូតជប៉ុន រួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) និងមជ្ឈមណ្ឌលអាស៊ីនៃមូលនិធិជប៉ុន (JFAC) នឹងរៀបចំនូវព្រឹត្តិការណ៍ "ពិធីបុណ្យផ្កាយអនឡាញ២០២១" ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ ជំនួសឲ្យព្រឹត្តិការណ៍ដែលធ្វើជារៀងរាល់ឆ្នាំគឺ "ពិធីបុណ្យផ្កាយ" ដែលរៀបចំឡើងតាំងពីឆ្នាំ២០០៤ ក្នុងគោលបំណងបន្តជម្រុញការផ្លាស់ប្តូរវប្បធម៌រវាងប្រទេសជប៉ុន និងកម្ពុជា។

តាណាបាតា ឬ ពិធីបុណ្យផ្កាយ គឺជាព្រឹត្តិការប្រពៃណីមួយរបស់ជប៉ុន ដែលតែងតែប្រារព្ធឡើងនៅថ្ងៃទី៧ ខែកក្កដា នៅប្រទេសជប៉ុន ដែលរំឮកដល់រឿងរបស់គូស្នេហ៍មួយគូនៅឋានសួគ៌ គឺនារីតម្បាញ និងបុរសគង្វាលគោ ដែលអ្នកទាំងពីរត្រូវបានបំបែកចេញពីគ្នាដោយទន្លេអាម៉ាណុហ្គាវ៉ា ហើយត្រូវបានអនុញ្ញាតឱ្យជួបគ្នាវិញ តែម្តងគត់ក្នុងមួយឆ្នាំ គឺនៅថ្ងៃទី ៧ ខែកក្កដា។ នៅថ្ងៃនោះ ប្រជាជនជប៉ុន សរសេរបំណងប្រាថ្នារបស់ពួកគេ ហើយព្យួរនៅលើដើមឫស្សី ដើម្បីឲ្យសម្រេចបានដូចបំណងប្រាថ្នា។

ក្នុងអំឡុងពេលនៃ ពិធីបុណ្យផ្កាយអនឡាញ២០២១ ចាប់ពីថ្ងៃទី ៩-១១ ខែកក្កដាឆ្នាំ ២០២១ នឹងមានកម្មវិធីវប្បធម៌ជប៉ុនតាមអនឡាញជាច្រើន នៅលើទំព័រហ្វេសប៊ុកព្រឹត្តិការណ៍ពិធីបុណ្យផ្កាយអនឡាញ២០២១ (សូមមើលLinkខាងក្រោម) ដូចជាថ្នាក់គំនូសរបស់អក្សរផ្ចង់បែបជប៉ុន ថ្នាក់ចម្អិនម្ហូបជប៉ុនជាមួយចុងភៅលោកទូត ដំណើរកម្សាន្តនៅទីក្រុងតូក្យូតាមរយៈZoom រៀនភាសាជប៉ុនជាមួយគ្នាតាមអនឡាញ រឿងនិទានអមដោយរូបភាព «តាណាបាតា,ទិព្វសូដាច័ន្ទ» វីដេអូស្តីពីវប្បធម៌ជប៉ុនផ្សេងៗ និងកម្មវិធីជាច្រើនទៀត។ កាលវិភាគពេលវេលានៃកម្មវិធីនីមួយៗមានភ្ជាប់ជាមួយ។

សម្រាប់ការសាកសួរព័ត៌មាន សូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរស័ព្ទលេខ ០២៣ ២១៧ ១៦១ (លេខភ្ជាប់បន្ត ១១២១) ឬផ្ញើអ៊ីម៉ែលមក៖ info.jpn@pp.mofa.go.jp។ សម្រាប់ព័ត៌មានបន្ថែមស្តីពីពិធីបុណ្យនេះ សូមចូលទៅកាន់ទំព័រហ្វេសប៊ុកនៃពិធីបុណ្យផ្កាយអនឡាញ២០២១៖ https://fb.me/e/4maLxGM5B៕

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*